

# វិស័យអប់រំកាតូលិក





ប្រចាំភូមិភាគភ្នំពេញ


ប្រព័ន្ធអប់រំទាំងមូល
សុខភាព / កីឡា
សង្គម / សិក្ខាសាលា
ចំណេះដឹង / ជំនាញ
វិញ្ញាណ / ចិត្តវិទ្យា
ការិយាល័យជីវិតនិស្សិត
ការស្រាវជ្រាវ / បណ្ណាល័យ
មិត្តភាព / ការជប់លៀង
មណ្ឌលនិស្សិត
សាមគ្គីភាព
ទេពកោសល្យ / ក្លឹប

# មាតិកា

## ប្រព័ន្ធអប់រំទាំងមូល


សាលាមត្តេយ្យសិក្សាព្រះសហគមន៍កាតូលិក ៥-១៤

- លទ្ធផលដែលសាលាមត្តេយ្យសិក្សាព្រះសហគមន៍កាតូលិកទទួលបាន
- អាសយដ្ឋាន

សាលាបឋមសិក្សាសហគមន៍វៀតណាម ១៥-១៨

- ស្ថិតិសិស្សនៃសាលាបឋមសិក្សាសម្រាប់ឆ្នាំសិក្សា ២០១៥-២០១៦
- អាសយដ្ឋានសាលាបឋមសិក្សាព្រះសហគមន៍កាតូលិក

វិទ្យាល័យចំណេះទូទៅនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សន្តហ្វ្រង់ស្វ័រ ១៩-២៤

- សមិទ្ធិផលដែលសាលាវិទ្យាល័យ សន្តហ្វ្រង់ស្វ័រសម្រេចបាន

វិទ្យាស្ថានសន្តប៉ូល ២៥-២៩

- លទ្ធផលនៃការបញ្ចប់បរិញ្ញាបត្រនៅវិទ្យាស្ថានសន្តប៉ូល

មជ្ឈមណ្ឌលវប្បធម៌និងភាសាបរទេស ៣០-៣២

- សមិទ្ធិផលដែលមជ្ឈមណ្ឌលវប្បធម៌និងភាសាបរទេសទទួលបាន

កម្មវិធីអានសៀវភៅក្រៅប្រព័ន្ធ ៣៣-៣៤

# ការិយាល័យសិក្សាកាតូលិក

## រចនាសម្ព័ន្ធ

ប្រធានការិយាល័យ
សិក្សាកាតូលិក
អ្នកស្រី ឡៃ មករា
អ៊ីមែល:
makara_lay01jan@yahoo.com
ទូរស័ព្ទលេខ:
017 / 081 575 686

អធិបតីលោកអភិបាល អូលីវីយេ

ប្រធានការិយាល័យផ្នែកសិក្សាកាតូលិក
អ្នកស្រី ឡៃ មករា

ក្រុមប្រឹក្សាភិបាល

ទំនាក់ទំនងជាមួយ
សាលាបព្វជិតបព្វជិតា

ទំនាក់ទំនងជាមួយ
មណ្ឌលនិស្សិតផ្សេងៗ

លេខាធិការ
អ្នកស្រី ទៀង សារ៉ន

គណនេយ្យ
លោក ស៊ុន នីន

មត្តេយ្យសិក្សា
អ្នកសម្រប
សម្រួល
អ្នកស្រី
ង៉ុយ គីម ច័ន្ទដារី

បឋមសិក្សា
អ្នកសម្របសម្រួល
លោក
លី សុធា

វិទ្យាល័យ
សន្តហ្វ្រង់ស្វ័រ
នាយក
លោក ប៊ុច វិបុល

វិទ្យាស្ថាន
សន្តប៉ូល
នាយករង
លោកសៀង ឡេង
កញ្ញា ម៉ែន ថារិន

មណ្ឌលវប្បធម៌
និងភាសាបរទេស
នាយក
លោក ហ៊ុន អាន

កម្មវិធីអាន
សៀវភៅ
នាយក
បងស្រី ស៊ីនកុ

# សាលាមត្តេយ្យសិក្សាព្រះសហគមន៍កាតូលិក

## Community Pre-School of Phnom Penh Catholic Church

សាលាមត្តេយ្យសិក្សាព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ
Community Pre-School of Phnom Penh Catholic Church



## ប្រវត្តិសាលាមត្តេយ្យសិក្សាព្រះសហគមន៍កាតូលិក

ក្រោយពីបានទទួលការតែងតាំង ជាអភិបាលព្រះសហគមន៍កាតូលិកប្រចាំភូមិភាគភ្នំពេញ បន្តមុខងារពីលោក អភិបាលអេមីល ដេតម្ប លោកអភិបាលអូលីវីយេ មានការចាប់អារម្មណ៍យ៉ាងខ្លាំងពីភាពខ្វះខាត ទុក្ខលំបាក អនក្ខរភាពរបស់ប្រជាជនកម្ពុជានៅតំបន់ជនបទដាច់ស្រយាលចុងកាត់មាត់ញក ជាពិសេសកុមារតូចៗ ដែលខ្វះការយកចិត្តទុកដាក់ថែទាំផ្គត់ផ្គង់អាហារូបត្ថម្ភ អនាម័យការសិក្សាអប់រំកាយ សីលធម៌រស់នៅ ដែលជាមូលដ្ឋានដ៏ចាំបាច់សម្រាប់អភិវឌ្ឍន៍អនាគតរបស់ពួកគេ ក៏ដូចជាសង្គមទាំងមូល។ ដោយមើលឃើញពីចំណុចស្នូលនេះ និងស្មារតីមេត្តាករុណាផងនោះ លោកអភិបាលអូលីវីយេ បានខិតខំអស់ពីកម្លាំង កាយចិត្ត សមត្ថភាព បទពិសោធន៍ និងលទ្ធភាព ដោយសម្រេចចិត្តបង្កើតសាលាមត្តេយ្យសិក្សាជាច្រើនកន្លែង ក្នុងភូមិភាគភ្នំពេញ ក្រោមបរិបទអប់រំទូលំទូលាយ ដោយមិនប្រកាន់សាសនា ជាតិសាសន៍ ពណ៌សម្បុរសញ្ជាតិ ឬនិន្នាការនយោបាយឡើយ ដោយគោរពតាមខ្លឹមសារអប់រំគោរពតាមគោលដៅអប់រំជាតិ គោលនយោបាយអប់រំកុមារតូច និងសិទ្ធិកុមារជាមូលដ្ឋាន ដោយមានការចូលរួមសហការពីក្រសួងអប់រំយុវជន និងកីឡានៃរាជរដ្ឋាភិបាលកម្ពុជា។

### ការអភិវឌ្ឍកុមារ

- រាងកាយ និងសុខភាព
- សីលធម៌ និងវប្បធម៌
- សង្គម និងអារម្មណ៍
- ការយល់ដឹង និងការពិចារណា
- ភាសា





# របៀបរៀនរបស់កុមារ

## កុមាររៀនដើម្បី

- សម្របខ្លួនទៅនឹងមជ្ឈដ្ឋានជុំវិញ
- ចង់ចេះ ចង់ដឹង ចង់ស្គាល់ ចង់យល់ ចង់ធ្វើឲ្យបានដូចអ្នកដទៃ និងមនុស្សធំ
- ចង់បង្ហាញអំពីអ្វីដែលជាទីមោទនភាពរបស់ខ្លួន
- អនុវត្តឲ្យទាន់ការលូតលាស់របស់សង្គមក្នុងពិភពលោក

## កុមាររៀនតាមរយៈ

- ការលេងជាមួយវត្ថុ រុក្ខជាតិ និងសកម្មភាពនានា
- ការចូលរួមសកម្មភាពងាយៗក្នុងបទពិសោធន៍ជីវិតពិត
- ការធ្វើដោយផ្ទាល់ដៃ និងគិតពីអ្វីដែលកំពុងធ្វើ
- ការរៀនពីមិត្តភក្តិ នៅពេលកំពុងលេងជាមួយគ្នា ឬកំពុងធ្វើសកម្មភាពអ្វីមួយ
- ការស្តាប់រឿងនានា ស្តាប់វិទ្យុ មើលទូរទស្សន៍ ភាពយន្ត មើលរូបភាពផ្សេងៗ
- ការនិទានរឿង ការសូត្រកំណាព្យ ការច្រៀង ការលេងតន្ត្រីកំសាន្ត
- ការប្រើប្រាស់ចំណេះដឹងមានស្រាប់
- ការសង្កេតមើលត្រាប់តាមកុមារដូចគ្នា និងមនុស្សចាស់
- ការព្យាយាមធ្វើកិច្ចការណាមួយ និងរៀនពីកំហុសនានា
- ការបង្រៀន ឬពន្យល់ ឬជួយធ្វើកិច្ចការឲ្យមិត្តភក្តិ
- ការស្តាប់តាមការណែនាំ បង្ហាត់បង្ហាញពីគ្រូ និងមនុស្សធំនៅជិតនិងនៅជុំវិញខ្លួន

ក្រៅពីកម្មវិធីសិក្សាខាងលើសាលាមត្តេយ្យព្រះសហគមន៍កាតូលិកបានបន្ថែមនូវកម្មវិធីម៉ុងតេសូរីដែលធ្វើឲ្យកុមារចេះឯករាជ្យខ្លួនឯងនិងចេះទទួលខុសត្រូវ។ បន្ទាប់ពីបញ្ចប់ការសិក្សានៅសាលាមត្តេយ្យ កុមារតូចៗទាំងនោះអាចចូលរៀននៅសាលាបឋមសិក្សាថ្នាក់ទី១ យ៉ាងមានក្តីអំណរសប្បាយ ដោយនៅក្នុងកម្មវិធីមត្តេយ្យសិក្សាបានបញ្ចូលកម្មវិធីសិក្សារបស់រដ្ឋ។





# ទស្សនវិស័យ

ព្រះយេស៊ូមានព្រះបន្ទូលថា៖ ខ្ញុំមកដើម្បីឲ្យមនុស្សលោកមានជីវិត ហើយឲ្យគេមានជីវិតពេញបរិបូរណ៌(យហ១០,១០)។ ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានគោលបំណងផ្តល់ការគាំពារនិងសេវាអប់រំដល់កុមារតូចៗនៅប្រទេសកម្ពុជា ដើម្បីធ្វើឲ្យអនាគតពួកគេក្លាយជាពលរដ្ឋល្អដែលមានគុណភាព និងជីវិតពេញបរិបូរណ៌មានភាពរុងរឿងនិងមានសុភមង្គលសម្រាប់គ្រួសារនិងប្រទេសជាតិ។

# បេសកកម្ម

អ្នកអប់រំនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញប្តេជ្ញាចិត្តផ្តល់ការគាំពារ និងសេវាអប់រំដល់កុមារតូចៗ ចាប់ពីអាយុ ៣ឆ្នាំ ដល់ក្រោមអាយុ៦ឆ្នាំ ដោយផ្អែកលើសិទ្ធិកុមារជាមូលដ្ឋាន ដើម្បីជួយពួកគេឲ្យអភិវឌ្ឍលើគ្រប់វិស័យ (រាងកាយនិងសុខភាព ការគិតពិចារណាមានហេតុផល ភាសា សង្គម សិល្បៈ វប្បធម៌ និងប្រពៃណី) និងមានសក្តានុពលពេញលេញក្នុងការត្រៀមខ្លួនចូលរៀននៅបឋមសិក្សា និងរៀនទៅថ្នាក់លើបន្តបន្ទាប់ប្រកបដោយប្រសិទ្ធិភាពនិងគុណភាព។

# គុណធម៌ ( គុណតម្លៃ )

ដើម្បីធានាប្រសិទ្ធិភាព និងគុណភាពក្នុងការគាំពារនិងសេវាអប់រំដល់កុមារតូចៗ អ្នកអប់រំនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញត្រូវតាំងខ្លួនជាមាតាទី២និងជាទីប្រឹក្សាដ៏ល្អ។ មានន័យថា អ្នកអប់រំកុមារតូចៗ មានគុណធម៌ និងសីលធម៌រស់នៅល្អជាទីទំនុកចិត្តរបស់កុមារប្រកបដោយមនសិការវិជ្ជាជីវៈខ្ពស់ ដែលអាចឲ្យកុមារមានបុគ្គលិកលក្ខណៈសម្បត្តិល្អក្នុងការអនុវត្តគុណតម្លៃរបស់ខ្លួននៅក្នុងគ្រួសារនិងសង្គមជាតិ។

# ទិសដៅ

- ប្រមូលកុមារពុំមានលទ្ធភាពសិក្សាឲ្យបានចូលរៀន និងទទួលការគាំពារយ៉ាងកក់ក្តៅ
- លើកកម្ពស់សមត្ថភាពគ្រូមត្តេយ្យសិក្សាជាប្រចាំ
- អភិវឌ្ឍសាលាមត្តេយ្យសិក្សាព្រះសហគមន៍ឲ្យក្លាយជាទីមេត្រីភាពសម្រាប់កុមារ

ផ្អែកតាមគោលនយោបាយអប់រំកុមារតូចៗ(រៀបចំដោយក្រសួងអប់រំយុវជននិងកីឡា) ក្នុងនោះមានកម្មវិធីអប់រំបញ្ចូលគ្នា ព្រះសហគមន៍កាតូលិកបង្កើតបាន២៤សាលាមត្តេយ្យសិក្សាព្រះសហគមន៍ ដែលមានលក្ខណៈស្តង់ដារជាតិ និងបានទទួលកុមារគ្រប់ប្រភេទមានកុមារក្រីក្រ កុមារពិការ កុមារងាយរងគ្រោះ និងកុមារជនជាតិ(ភាគច្រើនជាកុមារជនជាតិវៀតណាម)ឲ្យមកទទួលការអប់រំប្រកបដោយសមធម៌និងទទួលបានការគាំពារយ៉ាងកក់ក្តៅ។

# សាលាមត្តេយ្យសិក្សាព្រះសហគមន៍ បានបែងចែកជា៥តំបន់

## ១. អង្គការយូហ្វៀរ មាន៣សាលាមត្តេយ្យ ៖ សាលាមត្តេយ្យសិក្សា ចំប៉ា ស្វាយប៉ាក និងដីឥដ្ឋ

ស្ថិតិតាំងពីចាប់ផ្តើមដំណើរការ
សាលាមត្តេយ្យសិក្សា
រហូតដល់ឆ្នាំសិក្សា២០១៦





រូបភាពសលាមត្តេយ្យសិក្សានៅស្វាយប៉ាក

## ២. កំពត-តាកែវ បានបែងចែកជា៨កន្លែង សម្រាប់មត្តេយ្យសិក្សាព្រះសហគមន៍៖ សន្តីម៉ារីជុំគិរី កោះស្លា ព្រៃកប្រស់ ភ្នំវល្លិ៍ ចំការទៀង ភូមិសុខសាន្ត គិរីវង្ស ព្រៃកប្បាស

ស្ថិតិតាំងពីចាប់ផ្ដើមដំណើរការសាលាមត្តេយ្យសិក្សា រហូតដល់ឆ្នាំសិក្សា២០១៦





រូបភាពសាលាមត្តេយ្យសិក្សានៅចំការទៀង(តាកែវ)

## ៣. រាជធានីភ្នំពេញ បែងចែកជា២កន្លែងសម្រាប់មត្តេយ្យសិក្សា៖ បឹងទំពុន និង ផ្សារតូច




ស្ថិតិតាំងពីចាប់ផ្តើមដំណើរការ
សាលាមត្តេយ្យសិក្សា
រហូតដល់ឆ្នាំសិក្សា២០១៦



រូបភាពសាលាមត្តេយ្យសិក្សានៅបឹងទំពុន

## ៤. តំបន់ទន្លេបាសាក់ និងមេគង្គ (CCS) ចែកចេញជា៥សាលាមត្តេយ្យសិក្សាៈ ជ្រៃធំ ស្អាង សំប៉ាន កោះទៀវ ទួលក្រសាំង ផ្លូវត្រី




ស្ថិតិតាំងពីចាប់ផ្តើមដំណើរការ សាលាមត្តេយ្យសិក្សា រហូតដល់ឆ្នាំសិក្សា២០១៦



រូបភាពសាលាមត្តេយ្យនៅទួលក្រសាំង

## ៥. ក្រុងព្រះសីហនុ មានមត្តេយ្យសិក្សា៤កន្លែង៖ ត្រែងត្រយឹង បឹងតាព្រហ្ម រមាសងាប់ និង កោះខ្យង។

ស្ថិតិតាំងពីចាប់ផ្តើមដំណើរការសាលាមត្តេយ្យសិក្សារហូតដល់ឆ្នាំសិក្សា២០១៦






រូបភាពសាលាមត្តេយ្យនៅត្រែងត្រយឹង

# លទ្ធផលដែលសាលាមត្តេយ្យសិក្សាព្រះសហគមន៍ទទួលបាន

អាស្រ័យដោយក្តីស្រឡាញ់ចំពោះកុមារ រួមទាំងការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការបំពេញកាតព្វកិច្ចជាគ្រូមត្តេយ្យសិក្សាដ៏ល្អរបស់ព្រះសហគមន៍ បានធ្វើឲ្យកុមារទាំងអស់ (យូហ្វែរ កំពត និងតាកែវមានកុមារសរុប ៤១៩៩ នាក់ ក្នុងនោះកុមារីចំនួន ២៧៧០នាក់) ទទួលបានការសិក្សាល្អប្រកបដោយភាពកក់ក្តៅ មានសីលធម៌រស់នៅល្អ ចេះមានទំនាក់ទំនងល្អ ចុះសម្រុងទៅក្នុងសង្គម មានមូលដ្ឋានចំណេះដឹងដំបូងរឹងមាំនិងពោរពេញនូវសក្តានុពលអាចជាទុនឈានទៅរៀនថ្នាក់ទី១និងថ្នាក់លើបន្តបន្ទាប់នៅសាលាចំណេះដឹងទូទៅប្រកបដោយគុណភាព។ ទន្ទឹមនេះមាតាបិតា និងអាណាព្យាបាលកុមារកាន់តែយល់ច្បាស់អំពីសារៈសំខាន់នៃការអប់រំកូន និងចូលរួមសហការអប់រំឯកភាពរវាងសាលារៀននិងគ្រួសារបាន៥០% ដូចជាការបញ្ជូនកូនទៅសាលារៀនបានទាន់ពេលវេលានិងទៀងទាត់ ឈប់មានច្បាប់ បានផ្តល់ព័ត៌មានដែលទាក់ទងទៅនឹងកូនរបស់ពួកគាត់បានទាន់ពេល។



រូបភាពអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំ និងកូនសិស្សមត្តេយ្យ



# អាសយដ្ឋាន សាលាមត្តេយ្យសិក្សាព្រះសហគមន៍កាតូលិក

| ល.រ | សាលាព្រះសហគមន៍ | ភូមិ | ឃុំ / សង្កាត់ | ស្រុក / ខណ្ឌ | ខេត្ត / រាជធានី |
|---|---|---|---|---|---|
| អង្គការយូហ្វេរ | | | | | |
| ០១ | ចំប៉ា | ចេក | ចេក | ស្វាយជ្រុំ | ភ្នំពេញ |
| ០២ | ដីឥដ្ឋ | កោះផុសដីឥដ្ឋ | ដីឥដ្ឋ | កៀនស្វាយ | កណ្ដាល |
| ០៣ | ស្វាយប៉ាក | លូ | ស្វាយប៉ាក | ឫស្សីកែវ | ភ្នំពេញ |
| ០៤ | ភូមិបាំង(កំពង់ធំ) | បាំង | ចក្រី | បារាយ | កំពង់ធំ |
| តាកែវ- កំពត | | | | | |
| ០៥ | សន្តិម៉ារី ជុំគីរី | តារាជ | ត្រពាំងរាំង | ជុំគីរី | កំពត |
| ០៦ | កោះស្លា | ស្រែលាវ | ត្រពាំងភ្លាំង | ឈូក | កំពត |
| ០៧ | ព្រៃកប្រស់ | ព្រៃកប្រស់ | ទឹកថ្លា | ព្រៃនប់ | ព្រះសីហនុ |
| ០៨ | ភ្នំវល្លិ៍ | ចំការបី | ពងទឹក | ដំណាក់ចង្អើរ | កែប |
| ០៩ | ចំការទៀង | ចំការទៀង | គុស | ត្រាំកក់ | តាកែវ |
| ១០ | ភូមិសុខសាន្ត | ពងទឹកខាងត្បូង | គុស | ត្រាំកក់ | តាកែវ |
| ១១ | គិរីវង្ស | ព្រៃជើង | គោកព្រិច | គិរីវង្ស | តាកែវ |
| ១២ | ព្រៃកប្បាស | ព្រៃឈើទាល | ព្រៃផ្ដៅ | កប្បាស | តាកែវ |
| រាជធានីភ្នំពេញ | | | | | |
| ១៣ | បឹងទំពុន | ភូមិសន្សំកុសល៤ | បឹងទំពុន | មានជ័យ | ភ្នំពេញ |
| ១៤ | ផ្សារតូច | ផ្លូវជាតិ៥A | ទួលសង្កែ | ឫស្សីកែវ | ភ្នំពេញ |
| តំបន់ទន្លេមេគង្គ CCS | | | | | |
| ១៥ | ស្អាង | ព្រែករុន | ព្រែកគយ | ស្អាង | កណ្ដាល |
| ១៦ | សំប៉ាន | ក្បាលជ្រោយ | ពោធិបាន | កោះធំ | កណ្ដាល |
| ១៧ | កោះទៀវ | ព្រែកតាគួន | សំពៅពូន | កោះធំ | កណ្ដាល |
| ១៨ | ផ្លូវត្រី | ផ្លូវត្រី | ថ្មគរ | ល្វាឯម | កណ្ដាល |
| ១៩ | ជ្រៃធំ | ជ្រៃធំ | សំពៅពូន | កោះធំ | កណ្ដាល |
| ២០ | ទួលក្រសាំង | ទួលក្រសាំង | រកាខ្ពស់ | ស្អាង | កណ្ដាល |
| ក្រុងព្រះសីហនុ | | | | | |
| ២១ | ត្រែងត្រយឹង | ភូមិ២ | ត្រែងត្រយឹង | ភ្នំស្រួច | កំពង់ស្ពឺ |
| ២២ | បឹងតាព្រហ្ម | ភូមិបឹងតាព្រហ្ម | បឹងតាព្រហ្ម | ព្រៃនប់ | ព្រះសីហនុ |
| ២៣ | រមាសងាប់ | ភូមិរមាសងាប់ | បឹងតាស៊ី | ព្រៃនប់ | ព្រះសីហនុ |
| ២៤ | កោះខ្យង | ភូមិកោះខ្យង | អូរជ្រៅ | ព្រៃនប់ | ព្រះសីហនុ |

# សាលាបឋមសិក្សាសហគមន៍កុមារវៀតណាម

## Community Primary School for Vietnamese Children

ប្រវត្តិនៃការកកើតកម្មវិធីអក្ខរកម្មភាសាខ្មែរនេះ បានចាប់ផ្ដើមតាំងពីឆ្នាំ១៩៩៥ ក្រោមការជួយឧបត្ថម្ភពីអង្គការ (COERR) នៅប្រទេសថៃ។ ដំណើរការដំបូង មាន១៦សហគមន៍វៀតណាមទូទាំងភូមិភាគភ្នំពេញ មានក្នុងខេត្តព្រៃវែង កណ្ដាល និងរាជធានីភ្នំពេញ ដែលសហគមន៍ទាំងនោះជាព្រះសហគមន៍កាតូលិក។ អង្គការ (COERR) បានផ្ដល់ជំនួយឧបត្ថម្ភជាថវិកា រហូតដល់ឆ្នាំ២០០៣។ ដោយមើលឃើញថា ព្រះសហគមន៍កាតូលិក មានការរីកចម្រើនអាចទទួលខុសត្រូវបាន ទើបអង្គការ(COERR) បានផ្ទេរឲ្យព្រះសហគមន៍ ជាអ្នកគ្រប់គ្រងទាំងស្រុងនៅក្នុងឆ្នាំ២០០៤ ហើយព្រះសហគមន៍កាតូលិក បានពង្រីកគម្រោងរហូតដល់ ២២សហគមន៍ ដែលឧបត្ថម្ភដោយព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងក្រោមការណែនាំរបស់លោកអភិបាលអេមីល ដេតេម្ប៉។



នៅក្នុងឆ្នាំ២០១០ លោកអភិបាល អូលីវីយេ ត្រូវបានតែងតាំងជាអភិបាលប្រចាំភូមិភាគភ្នំពេញ។ បន្ទាប់មកលោកអភិបាល អូលីវីយេ បានយកចិត្តទុកដាក់ខ្ពស់ទៅលើគម្រោងសហគមន៍វៀតណាម ហើយខិតខំអស់ពីសមត្ថភាព ក្នុងការបើកដំណើរការសហគមន៍កោះទៀវឡើងវិញ និងបានបើកសាលាថ្មីៗបន្តបន្ទាប់ រហូតមកដល់បច្ចុប្បន្នមានសរុបចំនួន២១សហគមន៍ ដូចជា៖ ចំប៉ា ទួលតាំង កោះនរា រោងចក្រ ផ្លូវត្រី កំពង់ចម្លង ព្រែកដាច់ សំរោងធំ បឹងឈូក ទួលក្រសាំង ស្អាង សំប៉ាន ជ្រៃធំ តាហ៊ីង មាត់ក្រសាស់ អរិយក្សត្រ ស្វាយប៉ាក គីឡូលេខ៩ ចាក់អង្រែក្រោម កោះទៀវ



និងពោធិចិនតុង។ ដោយព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានអភិវឌ្ឍគ្រប់វិស័យ ជាពិសេសផ្នែកអប់រំមានការទទួលស្គាល់ពីក្រសួងអប់រំយុវជននិងកីឡា។

កម្មវិធីអក្ខរកម្មក៏បានអភិវឌ្ឍ ទៅជាសាលាបឋមសិក្សាព្រះសហគមន៍កាតូលិកវិញនៅឆ្នាំ២០១៣។ ក្នុងចំណោមសាលាអក្ខរកម្មទាំង២១សហគមន៍ កម្មវិធីសាលាបឋមសិក្សា បានជ្រើសរើសចំនួន១៣សាលា មានដូចជា៖ ចំប៉ា ទួលតាំង កោះនរា រោងចក្រ ផ្លូវត្រី កំពង់ចម្លង ព្រែកដាច់ សំរោងធំ បឹងឈូក ទួលក្រសាំង ស្អាង សំប៉ាន និងជ្រៃធំ។ ចំណែកសាលាចំនួន៦កន្លែងទៀត ជាកម្មវិធីអក្ខរកម្មមានដូចជា៖ តាហ៊ីង មាត់ក្រសាស់ អរិយក្សត្រ គីឡូលេខ៩ ចាក់អង្រែក្រោម និងកោះទៀវ (សាលានេះបានបិទ ហើយបន្ទាប់ពីសិស្សទៅរៀនបន្តជាមួយសាលារដ្ឋអស់គ្មានសិស្សថ្មីចុះឈ្មោះចូលរៀនទៀតចាប់តាំងពីថ្ងៃទី២៩ ខែវិច្ឆិកាឆ្នាំ២០១៣)។ គម្រោងសាលាបឋមសិក្សាព្រះសហគមន៍កាតូលិកថ្មីនេះមានកម្មវិធីសិក្សា និងម៉ោងសិក្សាដូចជាសាលារដ្ឋ។

ចំណែកគ្រូបង្រៀនកម្មវិធី សាលាបឋមសិក្សាព្រះសហគមន៍កាតូលិកបានប្រកាសជ្រើសរើសគ្រូ ដែលមានគុណកោសល្យ និងមានបទពិសោធន៍បង្រៀន។ ជាពិសេសកម្មវិធីបានជ្រើសរើសគ្រូចេញពីកម្មវិធីអក្ខរកម្ម (ជាគ្រូសាលារដ្ឋ) និងគ្រូមកពីសាលារដ្ឋផងដែរ។ គម្រោងនេះនឹងជួយបង្កើនការគាំទ្រ និងការទុកចិត្តពីសំណាក់ឪពុកម្ដាយ និងជួយអោយកុមារទាំងអស់ថ្នាក់ទី១ និងទី២ បន្តការសិក្សាថ្នាក់ទី៣នៅសាលារដ្ឋផ្សេងៗ។

## គោលបំណងកម្មវិធី

កម្មវិធីសាលាបឋមនឹងប្រមូលកុមារក្រីក្រមកពីគ្រួសារខ្មែរ វៀតណាមនិងចាម ដែលស្ថិតក្នុងសហគមន៍រៀបរាប់ខាងលើដើម្បីៈ

១/ជួយឲ្យពួកគេមានមូលដ្ឋានគ្រឹះដើម្បីបន្តការសិក្សានៅបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ ឬមហាវិទ្យាល័យដូចកុមារទូទៅ

២/ជំរុញឲ្យមានធនធានមនុស្សប្រកបដោយគុណភាពសម្រាប់អនាគតការងារនៅក្នុងប្រទេសកម្ពុជា

៣/ជួយឲ្យពួកគេរៀនអប់រំជំនឿនិងចូលរួមសកម្មភាពព្រះសហគមន៍ផ្សេងៗ ពីព្រោះពួកគេភាគច្រើនជាគ្រីស្តបរិស័ទ

៤/ផ្តល់មូលដ្ឋានគ្រឹះនៃសីលធម៌ សុជីវធម៌ និងរបៀបរស់នៅសម្រាប់ការប្រាស្រ័យទាក់ទងគ្នាប្រចាំថ្ងៃ

៥/បង្រៀនភាសាខ្មែរដើម្បីឲ្យពួកគេអាចប្រើប្រាស់ភាសាខ្មែរសម្រាប់របរចិញ្ចឹមជីវិត ។

ក្រោយពីការបញ្ចប់ការសិក្សាថ្នាក់ទី១ និងទី២ កុមារទាំងនោះនឹងអាចបន្តការសិក្សារបស់ខ្លួននៅថ្នាក់ទី៣ និងថ្នាក់បន្តបន្ទាប់នៅសាលារដ្ឋ ដែលជាឱកាសដ៏ល្អដើម្បីឲ្យពួកគេនៅលាយឡំជាមួយនឹងកុមារខ្មែរដទៃទៀត ក្នុងការបង្កើតមិត្តភាព ការស្រឡាញ់ ការគោរព និងការចេះរស់នៅជាមួយគ្នាដូចជាបងប្អូន។



# សាលាបឋមសិក្សា ឆ្នាំសិក្សា២០១៥-២០១៦









# អាសយដ្ឋាន ទីតាំងសាលាបឋមសិក្សា ព្រះសហគមន៍កាតូលិក

| ល-រ | សាលា ព្រះសហគមន៍ | ភូមិ | ឃុំ/សង្កាត់ | ស្រុក/ខណ្ឌ | ខេត្ត/រាជធានី | បញ្ជូនសិស្សទៅសាលារដ្ឋថ្នាក់ទី៣ |
|---|---|---|---|---|---|---|
| ០១ | ចំប៉ា | ជ្រោយអំពិល | ក្បាលកោះ | ច្បារអំពៅ | ភ្នំពេញ | សាលាបឋមសិក្សាចំប៉ា |
| ០២ | ទួលតាំង | ដើមស្លែង | ច្បារអំពៅទី២ | ច្បារអំពៅ | ភ្នំពេញ | សាលាបឋមសិក្សាច្បារអំពៅ២ |
| ០៣ | កោះនរា | កោះនរា | និរោធន៍ | ច្បារអំពៅ | ភ្នំពេញ | សាលាបឋមសិក្សាឫស្សីស្រស់ |
| ០៤ | រោងចក្រ | ដីឥដ្ឋកោះ | ដីឥដ្ឋ | កៀនស្វាយ | កណ្ដាល | សាលាបឋមសិក្សាដីឥដ្ឋ |
| ០៥ | ផ្លូវត្រី | ផ្លូវត្រី | ថ្មគរ | ល្វាឯម | កណ្ដាល | សាលាបឋមសិក្សាផ្លូវត្រី |
| ០៦ | កំពង់ចម្លង | កំពង់ចម្លង | ព្រែកទន្លាប់ | លើកដែក | កណ្ដាល | សាលាបឋមសិក្សាហ៊ុនសែនកំពង់ចម្លង |
| ០៧ | ព្រែកដាច់ | ព្រែកដាច់ | ព្រែកដាច់ | លើកដែក | កណ្ដាល | សាលាបឋមសិក្សាហ៊ុនសែនព្រែកដាច់ |
| ០៨ | សំរោងធំ | ដើមត្រែង | សំរោងធំ | កៀនស្វាយ | កណ្ដាល | សាលាបឋមសិក្សាព្រែកត្រែង |
| ០៩ | បឹងឈូក | លេខ ១ក | ស្វាយរលំ | ស្អាង | កណ្ដាល | សាលាបឋមសិក្សាហ៊ុនសែនព្រែកសំរោង |
| ១០ | ទួលក្រសាំង | ទួលក្រសាំង | រកាខ្ពស់ | ស្អាង | កណ្ដាល | សាលាបឋមសិក្សាអ៊ីរ៉ូហា |
| ១១ | ស្អាង | ព្រែករុន | ព្រែកគយ | ស្អាង | កណ្ដាល | សាលាបឋមសិក្សាហ៊ុនសែនព្រែកគយ |
| ១២ | សំប៉ាន | ក្បាលជ្រោយ | ពោធិបាន | កោះធំ | កណ្ដាល | សាលាបឋមសិក្សាពិជ័យសាគរ |
| ១៣ | ជ្រៃធំ | ជ្រៃធំ | សំពៅពូន | កោះធំ | កណ្ដាល | សាលាបឋមសិក្សាសំពៅមាស |



# វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជន សន្តហ្វ្រង់ស្វ័រ

## LYCÉE Professionnel Saint François

## ប្រវត្តិនៃការកកើតវិទ្យាល័យសន្តហ្វ្រង់ស្វ័រ

នៅឆ្នាំ២០០២លោកបូជាចារ្យអូលីវីយេប្រធានព្រះសហគមន៍កាតូលិកចំការទៀងបានបើកវគ្គបំប៉នចំណេះដឹងពេលយប់ដល់សិស្សថ្នាក់ទី១១និងថ្នាក់ទី១២នៃវិទ្យាល័យអង្គរនាបក្នុងគោលបំណងជួយពង្រឹងឲ្យពួកគេមានសមត្ថភាពសមល្មមអាចប្រឡងបាក់ឌុបជាប់ ក៏ដូចជាកាត់បន្ថយការចំណាយលើការសិក្សារបស់ពួកគេ។ លើសពីនេះទៅទៀតលោកបានតាមដានលទ្ធផលបាក់ឌុបរបស់សិស្សទាំងនោះ ដោយយកចិត្តទុកដាក់បំផុត។

ឆ្លងតាមសកម្មភាពទាំងនេះលោកបានសង្កេតឃើញថាសិស្សមួយចំនួន ដែលបានប្រឡងបាក់ឌុបជាប់ពួកគេគ្មានសមត្ថភាពគ្រប់គ្រាន់ដើម្បីរកការងារធ្វើ ហើយក៏គ្មានលទ្ធភាពទៅបន្តការសិក្សា នៅមហាវិទ្យាល័យនានាឬសាលាបណ្តុះបណ្តាលជំនាញនៅទីក្រុងដែរ ព្រោះតែពួកគេមានជីវភាពក្រីក្រ។ ដោយសេចក្តីអាណិតស្រលាញ់និងចិត្តសប្បុរសធម៌មេត្តាករុណាចង់ជួយដល់សិស្សក្រីក្រទាំងនោះ ដើម្បីឱ្យពួកគេមានសមត្ថភាពជំនាញមួយច្បាស់លាស់អាចរកការងារធ្វើបានឬអាចអភិវឌ្ឍគ្រួសាររបស់គេបន្ទាប់ពីប្រឡងបាក់ឌុបរួច លោកបូជាចារ្យអូលីវីយេបានផ្តួចផ្តើមគំនិតបង្កើតវិទ្យាល័យឯកជនមួយដែលមានឈ្មោះថាវិទ្យាល័យចំណេះទូទៅនិងបណ្តុះបណ្តាលវិជ្ជាជីវៈសន្តហ្វ្រង់ស្វ័រដើម្បីផ្តល់លទ្ធភាពឱ្យសិស្សរៀនមុខវិជ្ជាចំណេះទូទៅផង និងជំនាញដោយមានទីតាំងស្ថិតនៅភូមិចំការទៀង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។

វិទ្យាល័យចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំសិក្សា ២០០៣-២០០៤ តាមលិខិតអនុញ្ញាតលេខ ១២៧៧ អយក.ប្រក របស់ក្រសួងអប់រំយុវជន និងកីឡា ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៣ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះសហគមន៍កាតូលិកប្រចាំភូមិភាគភ្នំពេញ។ វិទ្យាល័យសន្តហ្វ្រង់ស្វ័រ មានទីតាំងនៅកណ្តាលវាលស្រែ ក្នុងភូមិចំការទៀង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ជាមួយសិស្សនុសិស្សថ្នាក់ទី១០ មួយថ្នាក់ ចំនួន៣៦នាក់ ហើយឆ្នាំ២០០៨ សាលាក៏បានបើកថ្នាក់អនុវិទ្យាល័យផងដែរ។

ដោយមានការយកចិត្តទុកដាក់ពីសំណាក់ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ បង្រៀនប្រកបដោយបទពិសោធន៍ច្រើនឆ្នាំ និងការគោរពពីវិន័យយ៉ាងខ្ជាប់របស់សិស្សានុសិស្សក្នុងការសិក្សា ទើបធ្វើឲ្យសិស្សានុសិស្សថ្នាក់ទី១២ តាំងពីការប្រឡងក្នុងឆ្នាំសិក្សា ២០០៩-២០១៣ ទទួលបានលទ្ធផលជោគជ័យប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ១០០% និង ថ្នាក់ទី៩ ក្នុងឆ្នាំសិក្សា ២០១០-២០១៦ ប្រឡងជាប់១០០%។



រដ្ឋមន្ត្រី ក្រសួងអប់រំថ្មី ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន បានប្រមើលពីស្ថានភាពប្រទេសកម្ពុជា និងបានជួយជម្រុញឲ្យមានសាលាបច្ចេកទេសនៅកម្រិតវិទ្យាល័យដើម្បីឲ្យមានធនធានដ៏ល្អប្រសើរនៅក្នុងវិស័យសេដ្ឋកិច្ច លើផ្នែកកសិកម្ម ផ្នែកទេសចរណ៍ និងផ្នែកឧស្សាហកម្ម។ យោងតាមតម្រូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាល័យសន្តហ្វ្រង់ស្វ័របានអនុញ្ញាតឲ្យបើកទៅជាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជនសន្តហ្វ្រង់ស្វ័រនៅឆ្នាំសិក្សា២០១៥-២០១៦ លើមុខវិជ្ជាៈជំនាញកសិកម្មៈ សិស្សានុសិស្ស ២៩នាក់ សិក្សារយៈពេល៣ឆ្នាំ (ឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣) ដោយសិក្សាលើជំនាញឯកទេស២២ម៉ោង/១សប្តាហ៍រួមទាំងការអនុវត្តន៍ និងចំណេះទូទៅ១៤ក្នុងមួយសប្តាហ៍ ចំណែកជំនាញទេសចរណ៍នឹងចាប់ផ្តើមនៅឆ្នាំសិក្សា២០១៧។ បន្ទាប់ពីបញ្ចាប់ការសិក្សា សិស្សានុសិស្សនឹងទទួលបាននូវសញ្ញាប័ត្រកម្រិតទីបី ដែលមានតម្លៃស្មើ នឹងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ហើយមានការងារធ្វើបើកអាជីវផ្ទាល់ខ្លួនឬបន្តការសិក្សានៅមហាវិទ្យាល័យតាមជំនាញរបស់ខ្លួន។

### ផ្នែកបច្ចេកទេសកសិកម្ម អាចឆ្លើយតបទៅនឹងតម្រូវការចាំបាច់ដូចខាងក្រោមៈ

- ការបង្កើតថ្មី
- ធនធានមនុស្សប្រកបដោយសមត្ថភាពជំនាញ
- ធ្វើឲ្យកសិកម្មបែបប្រពៃណី ប្រែជាបច្ចេកទេសកសិកម្មទំនើប
- ផ្តល់ឱកាសក្នុងការផលិតនូវការកែច្នៃម្ហូបអាហារ ដើម្បីធ្វើការសហការជាមួយសហគ្រិន
- ការអនុវត្តន៍កសិកម្មប្រកបដោយសក្តានុពល លើជំនាញចិញ្ចឹមជ្រូក ការដាំបន្លែផ្សេងៗ...នៅជិតដីអនុវត្តរបស់សាលា

### ផ្នែកបច្ចេកទេសទេសចរណ៍ អាចឆ្លើយតបទៅនឹងតម្រូវការចាំបាច់ដូចខាងក្រោមៈ

- សមត្ថភាពជំនាញ
- ធនធានមនុស្សប្រកបដោយជំនាញសមត្ថភាព
- ការគ្រប់គ្រងល្អ សេវាកម្មល្អ ទំនួលខុសត្រូវខ្ពស់
- ផែនការអនុវត្តច្បាស់លាស់ (គ្រោងសាងសងរមណីដ្ឋានខ្នាតតូច ដោយមានសហគ្រាសសិប្បកម្ម ការសាងសង់ឆាកសម្តែងល្ខោន ក្នុងការស្វាគមន៍ និងបង្ហាញដល់ភ្ញៀវទេសទេសចរណ៍ជាតិ និងអន្តរជាតិ)
- រៀបចំកម្មវិធីទេសចរណ៍បែបវប្បធម៌ និងធម្មជាតិ (កំពត ភ្នំបូកគោ កែប និងភូមិសុខសាន្ត)

វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជនសន្តហ្វ្រង់ស្វ័រ គឺជាសាលាដំបូងគេបង្អស់ នៅក្នុងកម្ពុជាដែលចាប់ផ្តើមលើជំនាញទេសចរណ៍ និងសាលាជំនាញទី៤ ជាមួយការអនុវត្តលើផ្ទៃដីធំជាងសាលាបច្ចេកទសផ្សេងទៀតដើម្បីជួយ និងបម្រើដល់សិស្សានុសិស្សក្រីក្រនៅតំបន់ជនបទឲ្យមាន សមត្ថភាពជំនាញច្បាស់លាស់ ក្លាយទៅជាបុគ្គលប្រកបដោយគុណភាព ប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ សង្គមជាតិ និងពិភពលោក ដែលស្របនឹងទស្សនៈដ៏ទូលំ ទូលាយនៃការអប់រំមនុស្ស និងគុណតម្លៃផ្នែកប្រតិបត្តិហាត់ការងារ ដែលជាផ្នែកមួយនៃការរៀនពេញមួយ ជីវិត ព្រមទាំងរួមចំណែកកាត់បន្ថយនូវភាពក្រីក្ររបស់សង្គមជាតិ។
មិនតែប៉ុណ្ណោះសំណង់អគារសាលាបច្ចេកទេសថ្មីដ៏ទំនើប នឹងទទួលស្វាគមន៍សិស្សានុសិស្ស ចំនួន១២០នាក់ ពីបណ្តាសិស្សានុសិស្សគ្រប់ខេត្តព្រមទាំងមានអន្តេវាសិកដ្ឋានសម្រាប់សិស្សស្នាក់នៅផងដែរ។



# វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជនសន្តហ្វ្រង់ស្វ័រ

លោកអភិបាល អូលីវីយេ
អ្នកសម្របសម្រួល

លោក ប៊ិច វិបុល
នាយកវិទ្យាល័យ

- អ្នកស្រី ឡៃ មករា
  នាយិការង
  - លោក ជិ នី
    ជំនួយការនាយិការង
- លោក ហ៊ិន ឡុន
  រដ្ឋបាល
- អ្នកស្រីអ៊ិន កុសល
  ជំនួយការទូទៅ

លោក កុល ជៀង
នាយកទូទៅ

- អ៊ីន ធីវ
  - ជាងទូទៅ
- ចៀវ សុផានី
  - អ្នកអនាម័យ
- ក្រុមចុងភៅ
  - ១ ហ៊ិន សារ៉ុម
  - ២ ជួប សុខ
  - ៣ កែវ ទូច
  - ៤ ហង្ស សឿន

## ចំណេះដឹងទូទៅ (វិទ្យាល័យ)

1. លោក ប៊ិច វិបុល (គណិតវិទ្យា)
2. អ៊ួង យុម (សីលធម៌)
3. ណយ ភួង (អក្សរសាស្ត្រខ្មែរ)
4. ជិន កុសល (អក្សរសាស្ត្រខ្មែរ)
5. អែម ថុល (គណិតវិទ្យា)
6. ទា ចន្ទ (ជីវវិទ្យា)
7. អ៊ូ ហេង (ប្រវត្តិ-ភូមិវិទ្យា)
8. ម៉ាង ស៊ីន (ផែនដីវិទ្យា)
9. សយ សេម (គីមីវិទ្យា)

## ចំណេះដឹងទូទៅ (អនុវិទ្យាល័យ)

10. ជួប ញ៉ុញ (គីមីវិទ្យា)
11. យុន ភា (គីមីវិទ្យា)
12. យុន ប៊ុនធី (រូបវិទ្យា)
13. យុន សំអាត (អក្សរសាស្ត្រខ្មែរ)
14. ស្រី សំអុល (គណិតវិទ្យា)
15. ឈីន សុភឿន (ប្រវត្តិ-ភូមិវិទ្យា)
14. ជា សុគន្ធារី (ជីវវិទ្យា)

## វិជ្ជាជីវៈ

15. ជិ នី (អក្សរសាស្ត្រអង់គ្លេស)
16. មិត្ត ធិ (អក្សរសាស្ត្រអង់គ្លេស)
17. កេត វណ្ណៈ (អក្សរសាស្ត្រអង់គ្លេស)
18. សុខ រតនា (កុំព្យូទ័រ)
19. ឈុន សារិទ្ធ (កុំព្យូទ័រ)
20. យឹម វ៉ាន (កសិកម្ម អនុវត្តន៍)
21. ប៊ីស ចិន្តា (កសិកម្ម ទ្រឹស្តី)
22. ទិត្យ សារ៉ែន (តន្ត្រី)
23. ស៊ាង រ៉េ (កីឡា)
24. សុខ សុខុម (កីឡា)

## ចក្ខុវិស័យ បេសកកម្ម គុណធម៌ កម្មវិធីសិក្សា

ដើម្បីឲ្យការអប់រំបណ្តុះបណ្តាលទទួល បានជោគជ័យវិទ្យាល័យចំណេះទូទៅ និងបណ្តុះបណ្តាលវិជ្ជាជីវៈសន្តប្រ៊្វង់ស្វ៊រ បានកំណត់ ចក្ខុវិស័យ បេសកកម្ម គុណធម៌ កម្មវិធីសិក្សាដូចខាងក្រោមៈ

### ចក្ខុវិស័យ ដើម្បីឱ្យមនុស្សលោកមានជីវិត ហើយឱ្យមានជីវិតពេញបរិបូរណ៍

នេះជាព្រះបន្ទូលដកស្រង់ពីព្រះគម្ពីរដំណឹងល្អ ឆ្លុះបញ្ចាំងពីគោលការណ៍គរុកោសល្យយើង ដែលតម្រង់ឆ្ពោះទៅរកសេចក្តីពិតរបស់ជីវិត។ ជីវិតយើងមានតម្លៃថ្លៃថ្នូរ ដោយសារយើងចេះគោរពវប្បធម៌ និងជំនឿសាសនារបស់អ្នកដទៃ។

បេសកកម្មអប់រំបណ្តុះបណ្តាលសិស្សក្លាយទៅជាៈ មនុស្សឈ្លាសវៃប៉ិនប្រសប់ សុចរិតស្អាតស្អំ គោរពអ្នកដទៃ ឯករាជ្យម្ចាស់ការ និងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីកសាងជីវិតរស់នៅក្នុងសេចក្តីថ្លៃថ្នូរ និងសុខដុមរមនា។

### គុណធម៌ៈ ទំនួលខុសត្រូវ ភាពស្មោះត្រង់ សាមគ្គីភាព ការតស៊ូព្យាយាម ការយកចិត្តទុកដាក់កម្មវិធីសិក្សា

ដើម្បីសម្រេចនូវចក្ខុវិស័យ និងបេសកកម្មរបស់ខ្លួន វិទ្យាល័យបានកំណត់យកកម្មវិធីសិក្សាដែលមានមុខវិជ្ជាសំខាន់ៗដូចខាងក្រោមៈ

- គណិតវិទ្យា
- អក្សរសាស្ត្រខ្មែរ
- រូបវិទ្យា
- គីមីវិទ្យា
- ជីវវិទ្យា
- សីលធម៌-ពលរដ្ឋ
- ប្រវត្តិវិទ្យា
- ភូមិវិទ្យា
- ផែនដីវិទ្យា
- សេដ្ឋកិច្ច
- ភាសាអង់គ្លេស
- កុំព្យូទ័រ
- កសិកម្ម និង កីឡា









# សមិទ្ធិផល

- ២០០៣៖ សាងសង់អគារថ្មី១ខ្នង សម្រាប់វិទ្យាល័យ ដោយមានថ្នាក់រៀន៣បន្ទប់ បន្ទប់កុំព្យូទ័រ១ បន្ទប់ពិសោធន៍១ និងការិយាល័យសិក្សា១បន្ទប់។
- ២០០៨៖ សាងសង់អគារថ្មី១ខ្នងសម្រាប់ថ្នាក់អនុវិទ្យាល័យ ដោយមានថ្នាក់រៀន៣បន្ទប់ បន្ទប់ភាសា១បន្ទប់ បណ្ណាល័យ១បន្ទប់ បន្ទប់រៀនរួម ចំនួន២បន្ទប់ បន្ទប់ដាក់សម្ភារ១បន្ទប់ បន្ទប់ទឹកប្រុសនិងស្រី២បន្ទប់ កន្លែងញុំាបាយសម្រាប់សិស្សានុសិស្ស និងផ្ទះបាយ។
- ២០០៨៖ ខួប៥ឆ្នាំរបស់វិទ្យាល័យ
- ២០១៣៖ ពិធីគម្រប់ខួប១០ឆ្នាំរបស់វិទ្យាល័យ
- ២០១៤៖ សាងសង់បន្ទប់ទឹកថ្មីចំនួន៦បន្ទប់។
- សិស្សានុសិស្សនៃវិទ្យាល័យសន្តហ្វ្រង់ស្វ័រ មានសាលាដៃគូនៅក្រៅប្រទេសដូចជា Shin Ai ប្រទេសជប៉ុន Temasek ប្រទេសសិង្ហបុរី និង Saint Charles d´ Athis Mons ប្រទេសបារាំង ដើម្បីផ្លាស់ប្តូរវប្បធម៌ក៏ដូចជាទំនៀមទំលាប់ និង បង្កើតភាពសិទ្ធស្នាល។
- សិស្សថ្នាក់ទី១២៖ ៩ជំនាន់បានប្រឡងបាក់ឌុប ហើយក្នុងនោះមាន ៥ជំនាន់ដែលបានប្រឡងជាប់ ១០០% (ឆ្នាំសិក្សា ២០០៧,២០១០,២០១១, ២០១២,២០១៣) ។
- សិស្សថ្នាក់ទី៩៖ ៤ជំនាន់បានប្រឡងឌីប្លូមជាប់ ១០០% ជារៀងរាល់ឆ្នាំ (ឆ្នាំសិក្សា ២០១១,២០១២, ២០១៣, ២០១៤)
- ឆ្នាំសិក្សា២០១៤ សិស្សថ្នាក់ទី១២ ប្រឡងលើកទី១ និងលើកទី២ ប្រឡងជាប់បាន ៩១.៨៩% (សិស្សសរុប៣៧ នាក់ ជាប់បាន៣៤នាក់) ។
- ២០១២-២០១៣៖ ប្រកួតកីឡាថ្នាក់ជាតិ សម្រាប់បាល់ទាត់នារី នៅខេត្តកំពង់ចាម ។
- ២០១៣-២០១៤៖ ប្រកួតកីឡាថ្នាក់ជាតិ សម្រាប់បាល់ទាត់ និងបាល់បោះនារីនៅខេត្តកំពង់ឆ្នាំង ។






ស្ថិតសិស្សនៃវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
ឯកជនសន្តហ្វ្រង់ស្វ័រ ឆ្នាំសិក្សា២០១៥-២០១៦
35
30
25
20
15
10
5
0
19
29
30
14
23
18
28
17
13
16
19
23
19
16
ថ្នាក់ទី៧
ថ្នាក់ទី៨
ថ្នាក់ទី៩
ថ្នាក់ទី១០
ថ្នាក់ទី១០ បច្ចេកទេសកសិកម្ម
ថ្នាក់ទី១១
ថ្នាក់ទី១២


ប្រៀបធៀបលទ្ធផលប្រឡងថ្នាក់ជាតិទូទាំងខេត្តតាកែវ
និង អនុវិ. សន្តហ្វ្រង់ស្វ័រ
ប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ
100%
100%
100%
100%
93%
95%
96%
95%
២០១១
២០១២
២០១៣
២០១៤
%ទូទាំងខេត្តតាកែវ
%អនុវិ.សន្តហ្វ្រង់ស្វ័រ


ប្រៀបធៀបលទ្ធផលប្រឡងថ្នាក់ជាតិ
( ទូទាំងប្រទេស-ទូទាំងខេត្តតាកែវ-វិទ្យាល័យសន្តហ្វ្រង់ស្វ័រ )
ប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ
% ទូទាំងប្រទេស
% ទូទាំងខេត្តតាកែវ
% វិ.សន្តហ្វ្រង់ស្វ័រ
77.60%
76.67%
87.50%
72.76%
67.33%
100.00%
70.70%
53.76%
83.33%
77.79%
85.23%
97.30%
81.90%
85.86%
100.00%
82.88%
82.25%
100.00%
86.48%
90.85%
100.00%
86.77%
87.43%
100.00%
37.80%
46.99%
92.00%
២០០៦
២០០៧
២០០៨
២០០៩
២០១០
២០១១
២០១២
២០១៣
២០១៤

# វិទ្យាស្ថានសន្តប៉ូល

## Saint Paul Institute




វិទ្យាស្ថានសន្តប៉ូល(SPI) គឺជាគ្រឹះស្ថានអប់រំកាតូលិក ដែលផ្តល់ការអប់រំកម្រិតខ្ពស់ជាងគេ តែមួយគត់នៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានបង្កើតដោយលោកអភិបាលអូលីវីយេក្រោមការឧបត្ថម្ភគាំទ្រពីលោក-ស្រីជនជាតិសិង្ហបុរី ប៉េកហ្គី ហើយវិទ្យាស្ថាននេះត្រូវបានបង្កើតឡើង នៅក្នុងឆ្នាំ២០០៩។ នៅក្នុងនោះផងដែរ វិទ្យាស្ថានមានសិស្សនិស្សិតជាង៣៨០នាក់ រួមទាំងនិស្សិតអាហារូបករណ៍និងនិស្សិតបង់ថ្លៃសិក្សាដែលស្ថិតនៅកម្រិតផ្សេងៗ គ្នានៃកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រ។ SPI គឺជាវិទ្យាស្ថានមួយ នៅក្នុងប្រទេសកម្ពុជាដែលផ្តល់ការអប់រំថ្នាក់ ឯកទេសក្នុងវិស័យអប់រំមុខវិជ្ជាពិសេសៗ ដូចជា៖ មហាវិទ្យាល័យក្សេត្រសាស្ត្រ(កសិកម្ម) មហាវិទ្យាល័យ ព័ត៌មានវិទ្យា មហាវិទ្យាល័យគ្រប់គ្រងទេសចរណ៍ មហាវិទ្យាល័យអក្សរសាស្ត្រអង់គ្លេស និងមហាវិទ្យាល័យសង្គមកិច្ច។ វិទ្យាស្ថានសន្តប៉ូល គឺជាគ្រឹះស្ថានអប់រំខ្ពស់មួយនៅក្នុងប្រទេសកម្ពុជា ដោយមានភាពសហប្រតិបត្តិការជាដៃគូរជាមួយមហាវិទ្យាល័យកាតូលិកជាច្រើន និងសាកលវិទ្យាល័យនានានៅអាស៊ីប៉ូព៉ា និងសហគមន៍អាស៊ាន ដោយហេតុនេះហើយទើបធ្វើឲ្យវិទ្យាស្ថានសម្រេចបាននូវសមិទ្ធិផលជាច្រើន។ វិទ្យាស្ថានសន្តប៉ូលមានបុគ្គលិកប្រហែលជា៦១នាក់ ដោយមិនបានរាប់បញ្ចូលទាំងបុគ្គលិកសិក្សានោះទេ លើសពីនេះពួកយើងមានកិច្ចសហប្រតិបត្តិការយ៉ាងល្អជាមួយសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ បុគ្គលិកសិក្សា៣៨នាក់ទាំងអស់សុទ្ធតែបានបញ្ចប់ការសិក្សាប្រកបដោយគុណភាព រាប់បញ្ចូលទាំងបេក្ខជនបណ្ឌិត ៣រូប អនុបណ្ឌិត៣១រូប និងបេក្ខជនអនុបណ្ឌិត៦រូប ដែលត្រូវបានគាំទ្រដោយបុគ្គលិករដ្ឋបាល និងថែទាំ ២៣រូប ។ ជាងនេះទៅទៀត វិទ្យាស្ថានក៏បានរក្សាបណ្តាញទំនាក់ទំនងដ៏ធំមួយនឹង RUA ដើម្បីសហការនៅក្រោមកិច្ចព្រមព្រៀងនៃការផ្លាស់ប្តូរកម្មវិធីសិក្សា និងបុគ្គលិកសម្រាប់នាយកដ្ឋានក្សេត្រសាស្ត្រ(កសិកម្ម)។ វិទ្យាស្ថានសន្តប៉ូល មានទីតាំងនៅភូមិគរគី ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ (ខាងជើងផ្សារអង្គតាសោម ផ្លូវជាតិលេខ៣)។

## ចក្ខុវិស័យ

វិទ្យាស្ថានសន្តប៉ូលមានចក្ខុវិស័យក្នុងការប្រែក្លាយសង្គមកម្ពុជា ប្រជាធិបតេយ្យ ដែលជាកន្លែងនិស្សិតទាំងអស់ទទួលបានការអប់រំដោយផ្អែកទៅលើតម្លៃសីលធម៌ និងផ្តល់អំណាចដល់ពួកគេឲ្យដើរតួនាទីយ៉ាងសកម្មក្នុងការអភិវឌ្ឍប្រទេសជាតិមួយ។

## បេសកកម្ម

បេសកកម្មរបស់ វិទ្យាស្ថានសន្តប៉ូលគឺដើម្បីជំរុញក្តីសង្ឃឹម បណ្តុះការអប់រំ និងលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់មនុស្សតាមរយៈការអប់រំដ៏សំខាន់មួយដល់និស្សិត ដែលមានមូលដ្ឋានលើ សេចក្តីស្រឡាញ់។ ដូច្នេះការផ្តល់អំណាចដល់ពួកគេ ដើម្បីក្លាយជាពលរដ្ឋដែលមានទំនួលខុសត្រូវលើសកម្មភាពនានារបស់ពួកគេ គឺត្រូវបានផ្អែកលើមូលដ្ឋាននៃសេចក្តីស្រឡាញ់ និងសម្រាប់សេចក្តីថ្លៃថ្នូររបស់មនុស្សម្នាក់ៗផងដែរ។



## គោលដៅ៖

ផ្តល់នូវការអប់រំប្រកបដោយគុណភាព និងមានអត្ថន័យ ប្រសើរជាងលទ្ធផលនៃការប្រឡងទៅទៀត។ និស្សិត ត្រូវរៀនអំពីរបៀបសិក្សា របៀបរិះគិត និងរបៀបរស់នៅប្រកបដោយសុចរិត។ វិទ្យាស្ថានអាចសម្រេចបេសកកម្មរបស់ខ្លួនបាននៅពេលនិស្សិតចេះ៖

- ស្រឡាញ់ប្រទេសជាតិរបស់ខ្លួន ចេះអភិវឌ្ឍន៍ទេពកោសល្យរបស់ខ្លួន និងចេះលើកតម្កើងវប្បធម៌របស់ខ្លួន ។
- មានការយល់ដឹងនិងចេះទទួលស្គាល់ខ្លួនឯង និងអ្នកដទៃ ហើយចេះពេញចិត្តចំពោះភាពខុសប្លែកគ្នារវាងជាតិសាសន៍នានា និងមានស្មារតីមេត្តាករុណាដ៏ជ្រាលជ្រៅ។
- ចេះគិតគូរល្អិតល្អន់ត្រឹមត្រូវ ហើយមានការបញ្ចេញមតិប្រកបដោយប្រសិទ្ធិភាព។
- ដឹងច្បាស់ពីហេតុផលនៃការជឿទុកចិត្តរបស់ខ្លួន។
- មានការយល់ដឹងពីសង្គម និងមានស្មារតីទទួលខុសត្រូវក្នុងសង្គម។
- បង្កើនសមត្ថភាពទាំងបុគ្គលិកលក្ខណៈទាំងទេពកោសល្យជំនាញតាមរយៈការសិក្សា និងសកម្មភាពសិក្សាបន្ថែមដូចជាសិល្បៈ និងកីឡាជាដើម ។
- បង្កើតសមត្ថភាពនៃការរិះគិតពិចារណាដែលជាមាគ៌ាណែនាំដំណើរជីវិតរស់នៅរបស់ពួកគេ



### អាសយដ្ឋាន

វិទ្យាស្ថានសន្តប៉ូល ស្ថិតនៅ
ភូមិគរគី ឃុំតាភេម
ស្រុកត្រាំកក់ ខេត្តតាកែវ
នាយករង ម្ជូរ ស៊ាងឡេង
ទូរស័ព្ទ៖ ០១២ ២៤ ០៣ ៤១
អ៊ីម៉ែល៖ seangleng@gmail.com

# លទ្ធផលនៃការបញ្ចប់ការសិក្សារបស់និស្សិតតាមឆ្នាំនីមួយៗ

| ឆ្នាំសិក្សា | ដេប៉ាតឺម៉ង់ | កំរិតវប្បធម៌ | ចំនួនសិស្ស |
|---|---|---|---|
| 2012-2013 | ព័ត៌មានវិទ្យា | បរិញ្ញាបត្រ | ៤៩ |
| | ភ្ញៀត្រសាស្ត្រ | បរិញ្ញាបត្រ | ៥៤ |
| | ប្រព័ន្ធកសិកម្មចម្រុះ | បរិញ្ញាបត្ររង | ៥១ |
| 2013-2014 | ព័ត៌មានវិទ្យា | បរិញ្ញាបត្រ | ១៩ |
| | អក្សរសាស្ត្រអង់គ្លេស | បរិញ្ញាបត្រ | ២២ |
| | គ្រប់គ្រងទេសចរណ៍ | បរិញ្ញាបត្រ | ៧ |
| 2013-2014 | ព័ត៌មានវិទ្យា | បរិញ្ញាបត្រ | ១២ |
| | ភ្ញៀត្រសាស្ត្រ | បរិញ្ញាបត្រ | ២៧ |
| | អក្សរសាស្ត្រអង់គ្លេស | បរិញ្ញាបត្រ | ១៨ |
| | គ្រប់គ្រងទេសចរណ៍ | បរិញ្ញាបត្រ | ៩ |



យោងតាមការអង្កេតរបស់វិទ្យាស្ថានបានរកឃើញថា ៨៤%នៃចំនួននិស្សិតសរុបដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំសិក្សា ២០១៤-២០១៥ ទទួលបានការងារធ្វើជាមួយប្រាក់បៀវត្សសមរម្យចាប់ពី ១០០ដុល្លារអាមេរិច រហូតដល់ ៤៥០ដុល្លារអាមេរិចក្នុងមួយខែ និងមានប្រាក់បៀវត្សជាមធ្យមចំនួន ១៩៤ដុល្លារ។ ចំណូលជាមធ្យមដែលវិទ្យាស្ថានបានរកឃើញនេះគឺជាតួលេខដ៏ល្អសមរម្យមួយសម្រាប់អ្នកដែល ទើបតែបញ្ចប់ការសិក្សាថ្មីៗនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ តារាងខាងក្រោមបញ្ជាក់អំពីការកត់ត្រាព័ត៌មានលម្អិត និងប្រាក់ខែរបស់និស្សិតទៅតាមជំនាញនីមួយៗ៖

ស្ថិតិនិស្សិតទទួលបានការងារធ្វើតាមផ្នែកនីមួយៗក្នុងឆ្នាំសិក្សា ២០១៤-២០១៥

| | ព័ត៌មានវិទ្យា | កេរ្យត្រសាស្ត្រ | អក្សរសាស្ត្រអង់គ្លេស | គ្រប់គ្រងទេសចរណ៍ |
|---|---|---|---|---|
| ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សា | ១២ | ២ | ១៨ | ៩ |
| បំរើការងារក្នុងស្ថាប័នឯកជន | ១១ | ១៣ | ១៦ | ៨ |
| បំរើការងារស្ថាប័នរដ្ឋាភិបាល | ០ | ១ | ០ | ០ |
| សហគ្រិន | ១ | ១ | ១ | ០ |
| មិនទាន់ទទួលបានការងារធ្វើ | ០ | ៨ | ១ | ១ |
| គ្មានព័ត៌មាន | ០ | ៤ | ០ | ០ |
| ប្រាក់ខែខ្ពស់បំផុត | ២៨០ | ៤៥០ | ៤៥០ | ៣០០ |
| ប្រាក់ខែទាបបំផុត | ១៥០ | ១០០ | ១៤០ | ១០០ |
| ប្រាក់ខែជាមធ្យម | ១៩៤.៥៤$ | ១៩២.៨៥$ | ២០៥$ | ១៧០$ |

មិនតែប៉ុណ្ណោះនៅឆ្នាំសិក្សា ២០១៦-២០១៧ វិទ្យាស្ថានសន្តប៉ូល ត្រៀមខ្លួនជាស្រេចក្នុងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសលើប្រាំមួយមុខជំនាញ ដូចខាងក្រោម៖

- អភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រ
- គ្រប់គ្រងប្រព័ន្ធ និងបណ្តាញកុំព្យូទ័រ
- ផលិតកម្មដំណាំឈើហូបផ្លែ និងបន្លែ
- វេជ្ជសាស្ត្រសត្វ
- ភាសាអង់គ្លេស
- សណ្ឋាគារ និងបដិសណ្ឋារកិច្ច



## បណ្ណាល័យ

គោលដៅចម្បងនៃពហុប្រព័ន្ធផ្សព្វផ្សាយរបស់វិទ្យាស្ថានសន្តប៉ូល គឺសម្រាប់និស្សិត និងសាស្ត្រាចារ្យស្វែងរកសៀវភៅ ទស្សនាវដ្ដី CD-ROMs DVDs មានភាសាអង់គ្លេស និងភាសាខ្មែរ ការគ្របដណ្តប់ការផ្លាស់ប្តូរប្រធានបទ ផ្តោតសំខាន់លើវិទ្យាសាស្ត្រ អក្សរសាស្ត្រ និងសិល្បៈ។ បណ្ណាល័យក៏ជាកន្លែងដែលអាចឲ្យនិស្សិតទៅសិក្សាស្រាវជ្រាវ ក្នុងបរិយាកាសស្ងប់ស្ងាត់ និងភាពទាក់ទាញ។ បន្ទប់កុំព្យូទ័រធំៗចំនួនពីរ គឺបានរៀបចំឡើងសម្រាប់ការស្រាវជ្រាវតាមអនឡាញនិងមើលមាតិកានៃពហុប្រព័ន្ធផ្សព្វផ្សាយ។ ហើយបណ្ណាល័យក៏ជាកន្លែងដែលអាចឲ្យនិស្សិតបានទទួលយកចំណេះដឹងពីការអាននិងការផ្តល់ដំបូន្មានពីការអាន។អ្វីដែលសំខាន់ជាងនេះទៅទៀតវាជាកន្លែងដែលប្រសើរបំផុតដើម្បីលើកទឹកចិត្តឲ្យនិស្សិតមានភាពម្ចាស់ការលើការរៀនសូត្រ។



## អន្តេវាសិកដ្ឋាន

វិទ្យាស្ថានសន្តប៉ូលបានរៀបចំអគារចំនួន៣ សម្រាប់ទទួលនិស្សិតឱ្យស្នាក់នៅដោយមិនបង់ថ្លៃ ដែលមានចំងាយប្រហែល ៥០០ម៉ែត្រពីទីតាំងវិទ្យាស្ថាន។ អគារស្នាក់នៅចំនួនពីរសម្រាប់បុរស និង ១សម្រាប់នារី។ អគារមួយមានកម្ពស់ពីរជាន់ និងមាន ៩បន្ទប់ មានការិយាល័យមួយ បន្ទប់សិក្សាចំនួន១ បន្ទប់កុំព្យូទ័រចំនួន១ និងមានបន្ទប់ទឹកចំនួន១៦។ អគារអន្តេវាសិកដ្ឋានទាំងបីអាចទទួល និស្សិតឱ្យស្នាក់នៅចំនួន ២១៦ នាក់ជារៀងរាល់ឆ្នាំ ។



# មជ្ឈមណ្ឌលវប្បធម៌ និងភាសាបរទេស
## Foreign Language And Cultural Center

មជ្ឈមណ្ឌលវប្បធម៌ និងភាសាបរទេស បានបង្កើតឡើងតាំងពីឆ្នាំ ២០០៧ មកម្ល៉េះ ដែលមានអគារចំនួន១ខ្នង ២ជាន់ស្មើនឹង ០៨បន្ទប់ (ដែលមានបន្ទប់សិក្សាចំនួន 05បន្ទប់ បណ្ណាល័យ ០១បន្ទប់ បន្ទប់Computer ០១បន្ទប់ និងការិយាល័យ០១បន្ទប់។ មានបង្រៀនកុំព្យូទ័រ និងថ្នាក់ភាសាអង់គ្លេសក្រៅម៉ោង (English Part Time) លើសពីនេះទៅទៀតសាលាមានបង្រៀនបន្ថែមផ្នែក សិល្បៈរបាំ និងគំនូរសម្រាប់ប្អូនៗ ដែរមានបំណងចង់សិក្សាលើជំនាញនេះ។ រហូតមកដល់ឆ្នាំ ២០០៩ សាលាក៏បានចាប់ផ្តើមបើកថ្នាក់មត្តេយ្យ ភាសារខ្មែរ និងអង់គ្លេស រហូតមកដល់សព្វថ្ងៃនេះ។

ម៉ោងសិក្សាសម្រាប់ថ្នាក់មត្តេយ្យះ

សិក្សាចាប់ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ពេលព្រឹកចាប់ពីម៉ោង ៧.០០នាទី ដល់ម៉ោង ១០.៣០នាទី បង្រៀនស្របតាមកម្មវិធីរបស់ក្រសួងអប់រំ ពេលល្ងាចចាប់ពីម៉ោង ២.០០នាទីរសៀល ដល់ម៉ោង ៤.៣០នាទីរសៀល បង្រៀនជាភាសាអង់គ្លេស។

ស្ថិតិកុមារះ សម្រាប់ឆ្នាំសិក្សា ២០១៥-២០១៦ មជ្ឈមណ្ឌលវប្បធម៌ និងភាសាបរទេសមានសិស្សចំនួន៤ថ្នាក់ចែកចេញជាះ

- កម្រិតទី១ះ មានអាយុចាប់ពី៣ឆ្នាំ ដល់ ៤ឆ្នាំមានសិស្សសរុបចំនួន២១នាក់ ស្រី១០នាក់ រៀនមួយពេល ដែលមានកម្មវិធីសាលារដ្ឋ ដោយបញ្ចូលកម្មវិធីថ្មីៗមួយចំនួន និងភាសាចអង់គ្លេសផងដែរ។
- កម្រិតទី២ះ កុមារមានអាយុពី៤ឆ្នាំទៅ៥ឆ្នាំ មានសិស្សសរុបចំនួន២៣នាក់ ស្រី១៣នាក់ សិក្សាពេញមួយថ្ងៃ គឺព្រឹកជាភាសាខ្មែរ និងពេលរសៀលជាភាសាអង់គ្លេស។
- កម្រិតទី៣ះ កុមារមានអាយុ៥ឆ្នាំ ដោយមានសិស្សសរុប២២នាក់ ស្រី១៣នាក់ រៀនពីរ ពេលព្រឹកជាភាសាខ្មែរ និងពេលរសៀលជាភាសាអង់គ្លេស។
- កម្មវិធីម៉ុងតេស្សូរីះ ជាកម្មវិធីពិសេសមួយដាច់គេ នៅក្នុងខេត្តកំពត ដែលមណ្ឌលវប្បធម៌ និងភាសាបរទេសបានជ្រើសរើសរៀបចំកម្មវិធីនេះឡើង ដល់កុមារ មានភាពឯករាជ្យម្ចាស់ការខ្លួនឯង និងចេះទទួលខុសត្រូវ។

នៅក្នុងឆ្នាំសិក្សា២០១៧ មជ្ឈមណ្ឌលវប្បធម៌ភាសាបរទេស មានគម្រោងសាងសងអគារមត្តេយ្យសិក្សាថ្មី ជាលក្ខណៈកម្មវិធីម៉ុងតេស្សូរី។



## សមិទ្ធផលដែលសម្រេចបានកន្លងមក

- បានរៀបចំជួសជុល តុ កៅអី ទ្វារ និងបង្អួច ដើម្បីអាចប្រើប្រាស់ឡើងវិញបាន
- ចាក់សាបខាងក្រោយសាលាឲ្យមានកន្លែងសម្រាប់ក្មេងរត់លេង
- រៀបចំសួនច្បារខាងមុខសាលា
- ធ្វើខ្លោងទ្វារចូលសាលា
- ជួសជុលបង្កាន់ដៃសាសា
- ជួសជុលបន្ទប់ទឹក និងធ្វើបន្ទប់ដាក់សម្ភារ
- ចាក់ដីធ្វើតារាងបាល់ទះ និងទីធ្លាសម្រាប់ឲ្យកុមាររត់លេង
- ចាក់ដីខាងមុខទ្វារបងសម្រាប់កុមារញ៉ាំនំ និងសម្រាប់ឪពុកម្តាយចាំទទួលកូន
- ធ្វើបន្ទប់ថ្មី ០១ បន្ទប់នៅជាន់ទី២សម្រាប់ថ្នាក់ Partime
- ទិញសម្ភារ (តុ កៅអី) សម្រាប់ថ្នាក់មត្តេយ្យថ្មី

## លទ្ធផលដែលទទួលបានកន្លងមកសម្រាប់មត្តេយ្យសិក្សា

ក្រោយពីទទួលបានការពង្រឹងសមត្ថភាពគ្រូ មជ្ឈមណ្ឌលទទួលបាននូវលទ្ធផលមួយចំនួនដូចជាៈ

- គ្រូមានទំនុកចិត្តលើខ្លួនឯងក្នុងការបង្រៀន និងអប់រំដល់កុមារ
- គ្រូមានវិធីសាស្ត្រល្អៗជាច្រើនក្នុងការបង្រៀន
- ជួយឲ្យកុមារផ្លាស់ប្តូរឥរិយាបថមួយចំនួនដែលមានទម្លាប់មិនល្អពីផ្ទះ ឲ្យមានទម្លាប់ល្អ ទៅតាមសាលារៀនដែលបានបង្រៀនដល់ពួកគេ
- កុមារមានសកម្មភាពចូលរួមយ៉ាងសកម្មក្នុងការសិក្សា និងការធ្វើអនាម័យ
- ជួយកុមារឲ្យយល់ច្បាស់ពីភាពពក្លាហានរបស់ពួកគេកាន់តែខ្លាំងឡើង
- ឲ្យកុមារទទួលបាននូវភាពកក់ក្តៅ និងក្តីស្រលាញ់ និងការថ្នាក់ថ្នម

## ការលើកកម្ពស់សមត្ថភាពគ្រូមត្តេយ្យសិក្សា

ដើម្បីឲ្យសិស្សទទួលបាននូវភាពជោគជ័យបាន សាលាមត្តេយ្យក៏បានផ្តោតសំខាន់បំផុត ទៅលើការពង្រឹងសមត្ថភាពដល់លោកគ្រូ អ្នកគ្រូ និងអ្នកទទួលបន្ទុកថែទាំកុមារ ដូចជាៈ

- រៀបចំវគ្គបណ្តុះបណ្តាល និងទទួលការបំប៉នជារៀងរាល់ឆ្នាំ
- រៀបចំការប្រជុំបច្ចេកទេសលើការបង្រៀនជាមួយគ្រូជារៀងរាល់ខែ
- សម្របសម្រួល និងត្រួតពិនិត្យគ្រូ ផ្តល់មតិយោបល់កែលម្អឡើងវិញនូវចំណុចដែលខ្វះខាត
- រៀបចំផែនការសកម្មភាព
- អនុវត្តសកម្មភាពដែលបានរៀបចំ

## ផែនការបន្តសម្រាប់ឆ្នាំសិក្សា ២០១៥ - ២០១៦

- រៀបចំបង្កើតកម្មវិធីសិក្សាថ្មីៗក្នុងការបង្រៀន
- ធ្វើការពង្រឹងវិន័យបុគ្គលិកក្នុងអង្គភាព
- ទទួលការបំប៉នដល់គ្រូថ្មី សម្រាប់កម្មវិធីសិក្សាថ្មី ( ម៉ុនតេសូរី ឆ្នាំ២០១៥)
- រៀបចំកន្លែង និងទីធ្លាសម្រាប់សិស្សលេង និងហាត់កីឡា
- ឲ្យគ្រូបានចូលរួមទស្សនកិច្ចសិក្សា
- ជួយកុមារក្រីក្រដែលពុំមានលទ្ធភាពសិក្សា អាចបន្តការសិក្សាបាន
- ជួយលើកកម្ពស់ជនពិការ ឲ្យពួកគេអាចបន្តការសិក្សាបាន
- លុបបំបាត់នូវការរើសអើង ចំពោះអ្នកក្រីក្រ ជនពិការ ឬអ្នកផ្ទុកមេរោគអេដស៍
- ឲ្យកុមារមានអនាម័យល្អទាំងក្នុងនិងក្រៅសាលា
- ផ្តោតការយកចិត្តទុកដាក់ចំពោះកុមារ ពង្រឹងក្រមសីលធម៌ និងវិជ្ជាជីវៈ សម្រាប់មត្តេយ្យសហគមន៍

## គោលដៅ

ថ្នាក់មត្តេយ្យសហគមន៍ជាកន្លែងមួយដែលកុមារគ្រប់រូបចង់បាន ព្រោះវាមិនត្រឹមតែជាថ្នាលមួយសម្រាប់អប់រំថែទាំកុមារប៉ុណ្ណោះទេ វាក៏ជាកន្លែងសម្រាប់ឲ្យកុមារឈានទៅរកភាពជោគជ័យទៅថ្ងៃខាងមុខបាន ដោយហេតុនេះសាលាមានគោលបំណង ឲ្យកុមារមានសមត្ថភាពចេះគិតពិចារណា ចេះដោះស្រាយបញ្ហាចំពោះមុខ ខិតខំរៀនសូត្រ មិនតែប៉ុណ្ណោះ អាចធ្វើពួកគេចេះរស់នៅដោយ ចុះសម្រុងជាមួយអ្នកដទៃ ចេះធ្វើការជាក្រុម និងមានភាពទទួលខុសត្រូវចំពោះខ្លួនឯង និងមិត្តភក្តិរបស់គេផងដែរ ដើម្បីមានភាពងាយស្រួលរស់នៅក្នុងសង្គមដ៏ល្អប្រសើរ។ ម្យ៉ាងវិញទៀតសាលាក៏ផ្តល់ឱកាសឲ្យពួកគេចេះចូលរួមក្នុងកម្មវិធីផ្សេងៗដូចជា កម្មវិធីបើកបវេសនកាល ចូលរួមកម្មវិធីបុណ្យណូអែល បុណ្យកុមារអន្តរជាតិ១មិថុនា និងចូលរួមពិធីបុណ្យព្រះសហគមន៍ជាច្រើនទៀតផងដែរ ។







# កម្មវិធីអានសៀវភៅ (ក្រៅប្រព័ន្ធ)

## Informal Reading Program

## ទស្សនវិស័យ

ភាពជាមនុស្សមានរាងកាយ និងដួងវិញ្ញាណ គឺលក្ខណៈនៃព្រលឹង និងរូបធាតុ។ ដោយមានដួងវិញ្ញាណសក្តិសមរាងកាយបានក្លាយជារាងកាយមានជីវិត ហើយមានសេចក្តីថ្លៃថ្នូរជាមនុស្ស ដែលបំពាក់នូវរូបភាព និងក្តីស្រលាញ់របស់ព្រះជាម្ចាស់។ ដូចនេះនៅពេលពួកគេអានសៀវភៅ ពួកគេជឿថា ព្រះជាម្ចាស់បានមកធ្វើការងារជ្រៅទៅក្នុងដួងវិញ្ញាណរបស់ពួកគេម្នាក់ៗ។ ដូចនេះយើងជឿថាពួកគេ នឹងធ្វើវាឲ្យក្លាយជាជំនួយសម្រាប់ការរៀនសូត្រ ពេញមួយជីវិតរបស់ពួកគេ។

## បេសកកម្ម

បេសកកម្មរបស់សកម្មភាពបណ្ណាល័យ គឺជួយសម្រួលដល់លទ្ធភាពអានសៀវភៅរបស់មនុស្ស។ ១.តាមរយៈការអានសៀវភៅ ពួកគេត្រូវបានលើកទឹកចិត្តឲ្យមានការអភិវឌ្ឍន៍តក្កវិជ្ជានិងការគិតប្រកបដោយការត្រិះរិះទៅក្នុងការយល់ដឹង ការវិភាគនិងការកំណត់ពីតម្រូវការរបស់សង្គមក្នុងពេលជាមួយគ្នានៅប្រទេសកម្ពុជា។ ២.បណ្ណាល័យមានប្រមូលផ្តុំទៅដោយសៀវភៅទិន្នន័យ និងកំណត់ត្រា ឬឯកសារចាំបាច់ជាច្រើន ដែលរៀបចំទុកដាក់ដោយមានរបៀបរៀបរយ និងថែរក្សា ដែលផ្តល់ឱកាសដល់អ្នកប្រើប្រាស់ ហើយឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ។ ៣. បណ្ណាល័យចូល រួមចំណែកលើកស្ទួយ វប្បធម៌ ការសិក្សាស្រាវជ្រាវ និងការផ្ទេប្រឌិតរបស់មនុស្ស។ល។



ដើម្បីលើកកម្ពស់ដល់កុមារ និងយុវជន នៅតាមតំបន់ជនបទដាច់ស្រយាល ចេះយកចិត្តទុកដាក់ក្នុងការអានសៀវភៅ និងជាជំនួយដល់ពួកគេឲ្យចេះស្រលាញ់ចូលចិត្តក្នុងការអានសៀវភៅទូទៅ ទើបបងស្រីស៊ីនកុបង្កើតកម្មវិធីបណ្ណាល័យតាមតំបន់នៅក្នុងឆ្នាំ២០០៧ ដូចជានៅ៖

* មជ្ឈមណ្ឌលវប្បធម៌ និងភាសាបរទេស៖ មានបណ្ណាល័យធំទូលាយសម្រាប់ ប្អូនៗចូលអាន និងខ្ចីសៀវភៅ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ហើយក្នុងនោះ មានសៀវភៅដូចជា៖



- កិច្ចការទូទៅ 150 ក្បាល
- ទស្សនវិជ្ជានិងចិត្តវិជ្ជា 97 ក្បាល
- សាសនា 175 ក្បាល
- វិទ្យាសាស្ត្រសង្គម 279 ក្បាល
- ភាសា 484 ក្បាល
- វិទ្យាសាស្ត្រធម្មជាតិ និងគណិតវិទ្យា 208 ក្បាល
- វិទ្យាសាស្ត្រអនុវត្តបច្ចេកវិទ្យា 230 ក្បាល
- សិល្បៈ 112 ក្បាល
- អក្សរសាស្ត្រ និងវោហាសាស្ត្រ 1098 ក្បាល
- ផែនដីវិទ្យា និងប្រវត្តិសាស្ត្រ 121 ក្បាល
- ចំនួនសៀវភៅនៅជុំគិរី 550 ក្បាល
- ចំនួនសៀវភៅនៅព្រែកប្រស់ 550 ក្បាល
- ចំនួនសៀវភៅនៅកោះស្លា 550 ក្បាល
- ចំនួនសៀវភៅនៅគិរីវង្ស 786 ក្បាល
- ចំនួនសៀវភៅនៅចំការទៀង 350 ក្បាល

សម្រាប់កម្មវិធីអានសៀវភៅនៅជុំគិរី ព្រែកប្រស់ កោះស្លា គិរីវង្ស និងចំការទៀង គឺធ្វើនៅរៀងរាល់ចុងសប្តាហ៍ នៅថ្ងៃអាទិត្យ។ មិនត្រឹមតែការអានសៀវភៅនោះទេ គឺបងស្រីបានបញ្ចូលកម្មវិធី សុខភាពអនាម័យដល់កុមារទាំងនោះទៀត។ កុមារមានការសប្បាយរីករាយក្នុងការអានសៀវភៅ ទោះបីជាពួកគេមានពេលវេលាតិចក៏ដោយ។

## អាសយដ្ឋាន

បង ស្រី ស៊ីន កុ

អ៊ីម៉ែល៖

shinkocambodia363@yahoo.com.jp

លេខទូរស័ព្ទ៖

០១២ ២០០ ៤៨២



## ទស្សនៈ VISION

...ដើម្បីអោយមនុស្សលោកមានជីវិត
ហើយអោយគេមានជីវិតពេញបរិបូរណ៍ យហ ១០,១០

*... so that they might have life and have it more abundantly* Jn 10,10

## គុណធម៌ VALUES

ទំនួលខុសត្រូវ Responsibility

ភាពស្មោះត្រង់ Honesty

សាមគ្គីភាព Solidarity

ការតស៊ូ ព្យាយាម Struggle

ការយកចិត្តទុកដាក់ Commitment

## បេសកកម្ម MISSION

អប់រំបណ្តុះបណ្តាលសិស្ស និស្សិតឱ្យក្លាយទៅជា:
មនុស្សឈ្លាសវៃប៉ិនប្រសប់
និងសុចរិតស្អាតស្អំ
គោរពអ្នកដទៃ, ឯករាជ្យម្ចាស់ការ
និងស្មារតីទទួលខុសត្រូវខ្ពស់
ដើម្បីកសាងជីវិតរស់នៅ ក្នុងសេចក្តីថ្លៃថ្នូរ
និងសុខដុមរមនា

To form students
Competent and Honest
Respectful of the other, Free and Responsible
To build up their Life in Dignity and Harmony

សាលាមត្តេយ្យសិក្សាព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ
Community Pre-School of Phnom Penh Catholic Church


**ការិយាល័យសិក្សាកាតូលិកភូមិភាគភ្នំពេញ**

ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ប្រធានការិយាល័យ អ្នកស្រី ឡៃ មករា

+៨៥៥ ២៣ ៦៤ ០០ ៨៤១ / ១៧ ៥៧ ៥៦ ៨៦

catholiceducationoffice@gmail.com / makara_lay01jan@yahoo.com

www.catholiccambodia.org


